ញ៉ុក ថែម

# មហាវេស្សន្តរជាតក



កណ្ឌទី ៧

ផ្សាយចេញពី "មជ្ឈមណ្ឌលវប្បធម៌ខ្មែរ"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៦ គ.ស ២០០២

# មហាវេស្សន្តរជាតក

## សម្រាប់ទេសន៍

## ទី ៧

# កណ្ឌមហាពន

ប្រដាប់ដោយគាថា ៨០
បោះពុម្ពលើកទី ១
ចំនួន ១.០០០ ច្បាប់

## ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ
ព.ស ២៥០៩

Websites: WatKhemaraRatanaram.org or WatKhmers.org

# មហាវេស្សន្តរជាតក

## ទី ៧

## កណ្ឌមហាពន

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

គច្ឆន្តោ សោ ភារទ្វាជោ អទ្ទស អច្ចុតំ ឥសឹ និស្វាន តំ ភារទ្វាជោ សម្មោទិ ឥសិនា សហ ។

ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ ឮដំណឹងកាលនោះ រីជូជកព្រាហ្មណ៍ដើរចេញពីចេតបុត្របង្ហាញផ្លូវ ទៅដល់យល់មហាឥសីមួយរូប ឈ្មោះអច្ចុតមហាឫសីកូវ ជូជកក៏មានសេចក្តីត្រេកអរ សំណេះសំណាលជាមួយនឹងឥសី សូត្រសាន្ទូវបាទព្រះគាថាដូច្នេះ ៖

កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា ច មកសា អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតីតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ភោ តាបស បពិត្រព្រះតាបសឫសី ដ៏មានសិរីសួស្តីប្រសើរ អើយ អញខ្ញុំចង់សួរដណ្តឹងអម្ចាស់ អំពីកាលអ្នកមកកសាងផ្នួសបួស ជាមហាឫសី សូត្រមន្តចំរើនមេត្តាភាវនា នៅនាព្រៃស្ងាត់ជ្រងំម្នាក់ឯង រីជម្ងឺអាពាធព្យាធិ ញាំងបៀតបៀនពាធា អ្នកនៅនាអាស្រមបទនេះ ឬទេ? មួយសោត នាបីហៅទុក្ខភ័យចង្រៃឧបទ្រព អផ្សុក ពុំស្រណុក ជាកលិយុគនៅនាព្រៃសព្វថ្ងៃនេះ តើញាំងមានឬទេ ? បពិត្រព្រះ តាបសឫសីអើយ នាស្វែងរកផ្លែឈើ មើមឈើមកចិញ្ចឹមអាត្មា ដោយ អ្នកបួសនៅនាព្រៃនេះ តើញាំងមានឬទេ ? មួយសោត រីម្ទូស សុច ស្រាំង ស្រួយ ខ្ទួយ ក្អែប មមង់ មមាច កន្ទេចអាលផង ផ្សំប្រចទ្បំនីទៅ នូវពស់តូច ពស់ធំ ថ្លាន់ ថ្លែន ខ្យាដំរីផង។ មួយសោត រីម្រឹគពាទ្ប យង់ឃ្នងផងទាំងទ្បាយដ៏ច្រើន មានរាជសីហ៍ ដំរីព្រៃ សិង្ហ ខ្លា រមាស ទន្សោង ខ្លោង គោព្រៃផង តើញាំងមានឬទេ ? ចូរអ្នកថ្លែងសំដែង ប្រាប់ដោយនូវពំនិតហោង ។

តាបសោ អាហ ក្សិណនោះ តាបសឫសីស្តាប់ពាក្យជូជក ព្រាហ្មណ៍ហើយ ក៏សូត្រជាបាទគាថាដូច្នោះ ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

កុសលញ្ចេវ មេ ព្រហ្មេ អថោ ព្រហ្មេ អណាមយំ
អថោ ឧញ្ឆេន យាបេមិ អថោ មូលផលា ពហូ ។
អថោ ឌំសា មកសា ច អប្បមេវ សិរឹំសបា
វនេ វាឡមិគាកិណ្ណេ ហឹំសា មយ្ហំ ន វិជ្ជតិ ។
ពហូនិ វស្សបូគានិ អស្សមេ សម្មតោ មម
ណាភិជាណាមិ ឧប្បន្នំ អាពាធំ អមនោរមំ ។
ស្វាគតន្តេ មហាព្រហ្មេ អថោ តេ អទុរាគតំ
អន្តោ បវិស ភទ្ទន្តេ បាទេ បក្ខាលយស្សុ តេ ។
តិណ្ឌុកានិ បិយាលានិ មធុកេ កាសមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ ព្រហ្មេ វរំ វរំ
ឥទំបិ បានិយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហាព្រហ្មេ សចេ ត្វំ អភិកង្ខសីតិ ។

ព្រហ្មេ ហៃព្រាហ្មណ៍អើយ រីអញមកសាងផ្នួសបួសជាមហាឫសីនៅជាអំឡុងម្ល៉េះហើយ នាបីហៅមានជម្ងឺអាពាធព្យាធិអ្វី

នឹងមកបៀតបៀនអញឲ្យជាទុក្ខ មិនស្រណុកនឹងសូត្រមន្តចំរើនមេត្តាភាវនាពុំបាន ដូចជាថៅដណ្តឹងសួរអញនេះ ឥតអង្គឹមានឡើយ ។ មួយសោត ថៅព្រាហ្មណ៍អើយ រីនឹងស្វែងរកផ្លែឈើ មើមឈើមកចិញ្ចឹមជីវិតអាត្មា ដោយនូវអ្នកបួសនៅនាព្ធដំព្រៃនេះមានច្រើនហោង ។ មួយសោត ហៃថៅព្រាហ្មណ៍អើយ រីសុច ស្រួយ មមង់ មមាច កន្ទេចអាលនូវពស់ ក្អែប ខ្ទួយ ខ្យាដំរីផង ដ៏មានច្រើនក្តាត់ ដ៏ពាសពេញនីទៅនូវម្រឹគពាឡសាហាវផងទាំងឡាយជាដើម គឺរាជសីហ៍ ដំរីព្រៃ គោ ក្របី ខ្ទីង សិង្ហផង នឹងអាចមកបៀតបៀនអាត្មា ដូចថៅដណ្តឹងនោះ ឥតអង្គឹមានឡើយ ។

ព្រហ្មេ ហៃតាព្រាហ្មណ៍អើយ នាអញមកសាងផ្ទួសបួសអាស្រ័យនៅទីនេះជាអំឡុងម្ល៉េះហើយ តែងសូត្រមន្តចំរើនមេត្តាភាវនាជាច្រើនក្តាត់ហោង រីនឹងមានជម្ងឺអាពាធព្យាធិ ឲ្យជាទុក្ខពុំស្រណុកដល់មួយពេលនោះ ឥតអង្គឹមានឡើយ ។ ព្រាហ្មណ៍អើយ ថៅមកពីឋានឆ្ងាយសមក្តៅក្រហាយ ចូរថៅអញ្ជើញទៅងូត ផឹក ជម្រះអង្គសម្រង់ក្បាលត្រអាលចិត្ត ហើយអង្គុយសម្រាន្តហោង ។ ហៃថៅ

ព្រាហ្មណ៍អើយ បើព្រះស្ដេងឃ្លានអាហារ ក៏អញ្ជើញព្រះស្ដេងជ្រើសរើសរកផ្លែឈើឯណាទុំខ្ចីក្ដី ក៏មានទន្លាប់ ញ្ញោ បង្គោ សិរមាន់ សង្ឃ័រ ខ្វិត គុយ ស្រគំ ទុំល្អ ៗ សឹងប្រពៃ ឧត្ដមប្រឡាក់នូវទឹកឃ្មុំផ្អិត អញ្ជើញព្រះស្ដេងបរិភោគចុះ ។ ព្រាហ្មណ៍អើយ ទោះស្រេកទឹកសោត ចូរព្រះស្ដេងដងទឹកនៅអាងតូចនោះថ្លាត្រជាក់ក្រអូប គឺអញដងមក ពីជ្រោះភ្នំវង្កតកំណត់ត្រង់ស្រះបោក្ខរណី ព្រះស្ដេងកុំបីសន្ទិះចិត្ត ឡើយ ទោះបីមានប្រាថ្នាអ្វីក្ដីនោះ ចូរព្រះស្ដេងថ្លែងប្រាប់អញហោង ។

ជូជកោ អាហ ទើបតាជូជកសូត្រនូវបាទព្រះគាថាដូច្នេះ ៖

បដិគ្គហិតំ យំ ទិន្នំ សព្វស្ស អគ្ឃិយំ កតំ
សញ្ជយស្ស សកំ បុត្តំ សិវីហិ វិប្បវាសិតំ
តមហំ ទស្សនមាគតោ យទិ ជានាសិ សំស មេតិ ។

ភោ តាបស បពិត្រព្រះតាបសឫសីដ៏ចម្រើនអើយ រីផ្លែឈើ មើមឈើផងទាំងឡាយ គឺអ្នកប្រដាប់ជាអាហារក្រយាទទួលភ្ញៀវនោះ ក៏អញខ្ញុំទទួលយកគ្រាន់តែនឹងបរិភោគប៉ុណ្ណោះ ។ បពិត្រម្ចាស់អើយ ខ្ញុំនេះមិនប្រាថ្នាការឯទៀតឡើយ គឺព្រះបាទស្រីសញ្ជ័យ

Websites: WatKhemaraRatanaram.org or WatKhmers.org

ង៏ជាព្រះវររាជបិតា ទ្រង់ត្រាស់ប្រើអញខ្ញុំឲ្យមកទូលសួរព្រះរាជបុត្រសម្លាញ់ ត្បិតទ្រង់ប្រាសមកជាយូរលង់ហើយ តើអ្នកដឹងលំនៅព្រះបាទស្រីវេស្សន្តរ ព្រះអង្គគង់នៅត្រង់ឋានឯណាមិញ ក៏ចូរអ្នកសម្តែងថ្លែងប្រាប់អញខ្ញុំ ដោយនូវពាក្យពិត ក៏អញខ្ញុំនឹងទៅអញ្ជើញព្រះអង្គមកឆាប់ហោង ។

តាបសោ អាហ តាបសឫសីនោះ ស្តាប់ពាក្យព្រាហ្មណ៍ស្រដីពីរោះ យល់ហាក់ដូចឆ្ពោះមានបើប្រាថ្នា ទើបសាស្ងូត្រជាបាទគាថាដូច្នេះ ៖

ន ភវំ ឯតិ បុញ្ញត្ថំ សិវិរាជស្ស ទស្សនំ
មញ្ញេ ភវំ បត្ថយតិ រញ្ញោ ភរិយំ បតិព្វតំ
មញ្ញេ កណ្ហាជិនំ ទាសិំ ជាលិំ ទាសញ្ច ឥច្ឆសិ
អថ វា តយោ មាតាបុត្តេ អរញ្ញា នេតុមាគតោ
ន តស្ស ភោគា វិជ្ជន្តិ ធនំ ធញ្ញញ្ច ព្រាហ្មណាតិ ។

ភោ ព្រាហ្មណ ហៃចៅព្រាហ្មណ៍អើយ ម្រាំងច្នោះឡើយរីព្រះស្ដែងព្រាហ្មណ៍ឯងនេះ មកប្រាថ្នាចង់យល់ព្រះបាទស្រីវេស្សន្តរ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាព្រះរាជបុត្រព្រះបាទស្រីសញ្ជ័យនោះ ថាបើអញគិតនេះសមយល់ នឹងប្រាថ្នាមកសុំសម្ដេចព្រះរាជមទ្រី ជាស្រីប្រកបនូវលក្ខណាប្រសើរ នោះក៏ពុំដឹង នឹងប្រាថ្នាមកសុំនាងក្រស្នាទៅធ្វើជាខ្ញុំស្រី ឬមួយមក សូមចៅជាលី ទៅធ្វើជាខ្ញុំប្រុសក៏ពុំដឹងឡើយ ។ រីព្រះបាទស្រីវេស្សន្តរ នោះ ព្រះអង្គគង់នៅនាព្រៃនេះ រីស្រូវអង្ករសំពត់អាវសៅស្បៃ សឹង គ្មានឡើយ ប្រាក់មាសខ្ញុំប្រុសស្រីមួយក៏គ្មាន ដំរី សេះ រទេះគោ ក្របី នោះសោតក៏គ្មាន មានតែប្រពន្ធនិងកូនសឹងបួសជាមហាឫសីហើយ តើព្រះស្តែងនឹងមានបើប្រាថ្នាអ្វីទៀត ។

តំ សុត្វា ជូជកោ អាហ ក្សិណនោះកូវ ជូជកព្រាហ្មណ៍ ស្តាប់ពាក្យមហាឫសី ស្រដីពុំពីរោះដូច្នោះ ហើយឆ្លើយវិញសូត្រជា បាទគាថាដូច្នេះ ៖

អក្កុទ្ធ្វោហំ ភោតោ ណាហំ យាចិតុមាគតោ
សាហុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ ។
អទិដ្ឋបុព្វោ សិវិរាជា សិវីហិ វិប្បវាសិតោ
តមហំ ទស្សនមាគតោ យទិ ជានាសិ សំស មេតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ភោ តាបស បពិត្រអ្នកតាមហាឫសីអើយ អ្នកពុំទាន់ស្ដាប់អស់សេចក្ដីរបស់អញខ្ញុំកូវ អ្នកដៀលទ្រគោះគំរោះ មកឲ្យអញខ្ញុំដូច្នោះ នេះហៅពុំគួរសមទេ នៃអ្នកតាអើយ អញខ្ញុំនឹងសម្ដែងថ្លែងប្រាប់អ្នកតា នាអញនេះ ជាព្រាហ្មណ៍មានសីលសត្យា អញខ្ញុំចង់យល់ព្រះបាទស្រីវេស្សន្តរ ជាអ្នកមានសីលពិព្យាយាមជាអ្នកបួសនោះ ក៏អញខ្ញុំនេះ តាំងពីកាលអ្នកស្រីពិរាស្រ្តគេបំបរបង់ព្រះអង្គនោះ មិនដែលបានដំណឹង មិនដែលបានយល់ព្រះអង្គឡើយ ហេតុនេះបានជាអញខ្ញុំមកដោយនូវព្រះបាទស្រីសញ្ជ័យព្រះអង្គប្រើមក។ ភន្តេ តាបស បពិត្រព្រះតាបសឫសីប្រសើរអើយ ទោះយោបីអ្នកដឹងលំនៅព្រះបាទស្រីវេស្សន្តរ ដ៏ជាក្សត្រប្រសើរនោះ ចូរអ្នកណែនាំប្រាប់អញខ្ញុំដោយនូវពិត រីបុណ្យគុណចំរើនដល់អ្នកនោះនឹងប្រាកដក្ដាត់ហោង ។

សោ តស្ស វចនំ សុត្វា សទ្ទហិត្វា ហោតុ ស្វេ តំ ទស្សិស្សាមិ តេ អជ្ជ តាវ ឥធេវ វសាហីតិ តំ ផលាផលេហិ សន្តប្បេត្វា បុនទិវសេ មគ្គំ ទស្សេន្តោ ទក្ខិណាហត្ថំ បសារេត្វា អាហ ។ ហៃសប្បុរសផងទាំងឡាយអើយ រីអច្ចុតមហាឫសីនោះ

ស្តាប់ពាក្យព្រាហ្មណ៍ស្រដីដូច្នោះហើយ ក៏ជឿថាមែនពិតស្មោះ ។ ក្សិណនោះ មហាឫសីយកអស់ផ្លែឈើទុំខ្ចីនោះ ឲ្យទៅព្រាហ្មណ៍បរិភោគស្រេចហើយ ទើបឲ្យតាជីសម្រាន្តអស់រាត្រីមួយ ។ លុះព្រឹកឡើងកូវ នាំព្រាហ្មណ៍នោះទៅបង្ហាញផ្លូវ ហើយលើកដៃស្តាំចង្អុលប្រាប់ថា ព្រហ្មេ ហៃព្រាហ្មណ៍អើយ គន្ត្វា ចូរព្រះស្តែងដើរទៅ ឯតំ មគ្គំ ឰដ៏ផ្លូវនេះឯងហោង ។

ឯស សេលោ មហាព្រហ្មេ បព្វតោ គន្ធមាទនោ
យត្ថ វេស្សន្តរោ រាជា សហ បុត្តេហិ សម្មតិ ។
ធារេន្តោ ព្រាហ្មណវណ្ណំ អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតិ ។
ឯតេ នីលា បទិស្សន្តិ នានាផលធរា ទុមា
ឧគ្គតា អព្ភកូដាវ នីលា អញ្ជនបព្វតា ។
ធវស្សកណ្ណា ខទិរា សាលា ផន្ទនមាលុវា
សម្បវេធន្តិ វាតេន សកឹ បីតាវ មាណវា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ឧបរិ ទុមបរិយាយេសុ		សង្គីតិយោវ សុយ្យរេ
នជ្ជុហា កោកិលា សង្ឃា		សម្បតន្តិ ទុមា ទុមំ ។
អវ្ហយន្តេវ  គច្ឆន្តំ		សាខា បត្តសមីរិតា
រមយន្តេវ អាគន្តុំ		មោទយន្តិ និវាសិនំ ។
យត្ថ វេស្សន្តរោ រាជា		សហ បុត្តេហិ សម្មតិ
ធារេន្តោ ព្រាហ្មណវណ្ណំ		អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ		ជាតវេទំ នមស្សតិ ។
កិរេរីមាលា វិតតា		ភូមិភាគេ មនោរមេ
សទ្ទលា ហរិតា ភូមិ		ន តត្ថុទ្ធំ សតេ រជោ ។
មយូរគីវសង្កាសា		តូលផស្សសមូបមា
តិណានិ នាតិវត្តន្តិ		សមន្តា ចតុរង្គុលា ។
អម្ពា ជម្ពូ កបិដ្ឋា ច		នីចេ បក្កា ចុទុម្ពរា
បរិភោគេហិ រុក្ខេហិ		វនន្តំ រតិវឌ្ឍនំ ។
វេឡុរិយវណ្ណសន្និភំ		មច្ឆគុម្ពនិសេវិតំ

Websites: WatKhemaraRatanaram.org  or  WatKhmers.org

សុចិ សុគន្ធំ សលិលំ អាបោ តត្ថបិ សន្ទតិ ។
តស្សាវិទូរេ បោក្ខរណី ភូមិភាគេ មនោរមេ
បទុមុប្បលសញ្ឆន្នា បោណ្ឌរិកាសមោតតា ។
តីណិ ឧប្បលជាតានិ តស្មឹ សរសិ ព្រាហ្មណ
វិចិត្រនីលានេកានិ សេតា លោហិតកានិ ចាតិ។

មហាព្រហ្មេ ហៃមហាព្រាហ្មណ៍ដ៏ចម្រើនអើយ រីភ្នំឯនាយនោះ សឹងដ៏រាបទាបរៀបរយ ពាសពេញនីទៅនូវថ្មស លោកសន្មតហៅថាភ្នំគន្ធមាទន៍បពិត ។ មហាព្រាហ្មណ៍អើយ រីព្រះបាទវេស្សន្តរបរពោធិសត្វ ព្រះអង្គទ្រង់ព្រះផ្នួសបួសជាមហាឫសី មួយអន្លើនូវព្រះរាជបុត្រាបុត្រី ព្រះរាជទេពី ព្រះអង្គទ្រង់នូវជ្រនីកទំពក់ ផ្ទក់ផ្លែឈើ ហើយអ្នកចងព្រះកេសាជាជដាមណ្ឌល ទ្រង់នូវស្បែកខ្លា ក្រវាត់ស្បូវភ្លាំង មានទាំងធម្មក្រកព្រនួនភ្លើង ទ្រង់នមស្ការបូជាព្រះភ្លើង តម្កើងរស្មីតាងចីវរព្រះបច្ចេកពោធិហោង ។

ព្រហ្មេ ហៃព្រាហ្មណ៍អើយ ទុមា ទុមំ រីផ្លែឈើតូចធំផងទាំងឡាយ បធិស្សន្តិ ដ៏យល់ប្រាកដ នីលវណ្ណា ដ៏មានពណ៌នោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ខ្មៅល្អដូចខ្លង់មេឃ គឺព្រហូត ស្តី ស្តៅ តាត្រៅ ឈើទាល ពពាលខែ ដ៏មានផ្លែផ្កានោះផ្សេងៗ ។ វីឈើនោះសោត សឹងដ៏មានត្របែក ត្រចៀក ប្រើស គគីរ រាំង ក្រសាំង ពង្រ ដកពរ អញ្ចាញ ពពូល ស្រូល ស្រល់ផងទាំងឡាយ ។ ព្រាហ្មណ៍អើយ វីអស់ឈើទាំងនោះសោត កាលណាបើខ្យល់បក់មកនោះ ដ៏មានចុងឱនលំទោនទៅមក បីដូចអ្នកប្រមឹកស្រាវាឱនព្រមគ្នាដូច្នោះ ។ មួយសោតព្រាហ្មណ៍អើយ វីសត្វបក្សីផងទាំងឡាយ ដ៏ទំឃំនៅលើចុងឈើនោះ បើអ្នកផងទាំងឡាយដើរទៅដើរមក សឹងដ៏ឮសព្ទពីរោះ បីដូចចំរៀងស្គួគិនាយ ។ ព្រាហ្មណ៍អើយ វីព្រះបាទស្រីវេស្សន្តរ ព្រះអង្គគង់មួយអន្លើនឹងព្រះរាជបុត្រ ព្រះរាជទេពី តែងទ្រង់ចំរើនមេត្រីដល់សត្វផងទាំងឡាយ ព្រះអង្គចងជដាមណ្ឌលតម្កល់ព្រះភ្លើងតម្កើងតាងចីវរ ព្រះបច្ចេកពោធិសង្ឃាតភាវនាពុំដែលដាច់ដល់មួយរាត្រីឡើយ ទ្រង់ប្រះសឹងលើកម្រាលស្លឹកឈើលើដីរឹងនោះហោង ។

ព្រហ្មេ ហៃព្រាហ្មណ៍អើយ វីភូមិលំនៅព្រះបាទស្រីវេស្សន្តរនោះ បីដូចអ្នកក្រងរំយោលព្យូរនូវភ្ញី បីដូចអ្នកបេះប្រឡេះចងព្យូរនៅ

Websites: WatKhemaraRatanaram.org or WatKhmers.org

សងខាងព្រះអាស្រមបទ ។ មួយសោត រីភូមិនោះរាប បីដូចផ្ទៃស្គរ សឹងដុះតែស្មៅជើងក្រាស់ ព្រាហ្មណ៍អើយ រីស្មៅនោះសោត រាបខៀវល្អ បីដូចផ្នួតកក្ងោកមាស រីខ្សាច់នោះសោត ក៏ល្អដូចសំឡីគេផ្ដេចបញ្ជី ៧ ដង រាបស្មើពុំកន្លងនឹងគ្នាឡើយ ។ មួយសោត ព្រាហ្មណ៍អើយ រីឈើនៅសងខាងផ្លូវនោះ ក៏មានផ្លែនោះ ទុំសំយុងចុះនៅព្វដ៏ឋានទាបហោង ។ ព្រាហ្មណ៍អើយ មួយសោត រីត្រីនិងអណ្ដើកផងទាំងឡាយសឹងដើរដោយអណ្ដាប់គ្នា នៅព្វដ៏ស្រះបោក្ខរណីនោះ ។ រីទឹកហូរចូលទៅក្នុងកំឡុងស្រះនោះសោត សឹងក្រអូបពិដោរនូវរសភ្ជី ឯស្រះបោក្ខរណីនោះ ក៏ពុំឆ្ងាយពីទីអាស្រមបទព្រះបាទស្រីវេស្សន្តរនោះឡើយ ។ ម្នាលព្រាហ្មណ៍អើយ រីស្រះបោក្ខរណីនោះសោត ដ៏ដេរដាសពាសពេញនីទៅនូវឈូកស ឈូកច្រាល កុមុទ ឧប្បល លំចង់ ស្បង្គ័ជព្រលិត ស្គន់ កំពីងពួយផងច្រើន ។ ហៃព្រាហ្មណ៍ព្រឹទ្ធាចារ្យអើយ រីកំណើតផ្កាឧប្បលផងទាំងឡាយ ដ៏មានពណ៌នោះ ៣ ជំពូក សឹងដ៏ល្អផ្សេងៗ ពីគ្នា ខ្លះក្រហម ខ្លះស ខ្លះខៀវ ដូចផ្កាសណ្ដោករាជមាស រីផ្កាឧប្បលទាំង ៣ ជំពូកនោះ កើតមាននាស្រះបោក្ខរណីនោះឯង ដ៏

Websites: WatKhemaraRatanaram.org or WatKhmers.org

រុងរឿងល្អបីដូចស្រះនន្ទនឧទ្យានឋានទេវតា នៅនាឋានចាតុម្មហារា-
ជិកាសួគ៌នាយហោង ។

ឯវំ ចតុរស្សបោក្ខរណី វណ្ណេត្វា បុន មុចលិន្ទសរំ វណ្ណេន្តោ អាហ ។ រីតាបសមហាឫសីនោះ សរសើរស្រះបោក្ខរណី នូវប្រការអម្បាលនោះហើយ ក៏មកសរសើរឯមុចលិន្ទស្រះវិញ សូត្រជាបាទព្រះគាថាដូច្នេះ ៖

ទោ មារ តត្ថ បទុមា សេតសោគន្ធិយេហិ ច
កាលម្ពកេហិ សញ្ឆន្នោ មុចលិន្ទោ នាម សោ សរោ ។
អថេត្ថ បទុមា ផុល្លា អបរិយន្តារ ទិស្សរេ
គិម្ហា ហេមន្តិកា ផុល្លា ជណ្ណុតគ្ឃា ឧបត្ថរា ។
សុរភី សម្បវាយន្តិ វិចិត្រា បុប្ផសន្ថតា
ភមរា បុប្ផគន្ធេន សមន្តាមភិនាទិតាតិ ។

ហៃព្រាហ្មណ៍អើយ រីស្រះមុចលិន្ទនោះ ដ៏ដេរដាសពាស ពេញនីទៅនូវឈូកស ឈូកក្រហម ឈូកខៀវ ដ៏មានផ្ការីករោយ ជម្រុះកេសរផ្កានៅឰដ៏កំឡុង ទឹកស្រះមុចលិន្ទនោះឯង ។ មួយសោត

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រាហ្មណ៍អើយ រីមុចលិន្ទស្រះនោះកូវ ទោះរដូវក្តៅក្តី ទោះរដូវរងាក្តី ដ៏ផ្កាឧត្បលនោះរីករោយប្រាកដ សឹងមាននៅនាទឹកជ្រៅទឹករាក់ ដ៏ពិដោរនីទៅនូវក្លិនភ្ញីផង រីកន្លង់ឯងសោត សឹងដ៏ហើរមកក្រេបកេសរភ្ញីព្វដ៏ស្រះមុចលិន្ទនោះ បីដូចត្រែសង្ខ តូរ្យតន្ត្រី ភ្លេងល្បែង បន្លែងនៅនាស្មូគិនាយនោះឯងហោង ។

អថេត្ថ ឧទកាន្តស្មឹ រុក្ខា តិដ្ឋន្តិ ព្រាហ្មណា
កទម្ពា ចាជលី ផុល្លា កោវិឡារា ច បុប្ផិតា ។
អង្កោលា កច្ចិការា ច ចារិជញ្ញា ច បុប្ផិតា
វារណា វុយ្ហជា រុក្ខា មុចលិន្ទមុកតោ សរំ ។
សិរីសា សេតចារិសា សាធុ វាយន្តិ បទ្មកា
និគ្គុណ្ឌី សរនិគ្គុណ្ឌី អសនា ចេត្ថ បុប្ផិតា ។
បង្គុរា ពហុលា សេលា សោភញ្ជនា ច បុប្ផិតា
កេតកា កណិការា ច កណវេរា ច បុប្ផិតា
អជ្ជុនា អជ្ជុកណ្ណា ច មហានាមា ច បុប្ផិតា

Websites: WatKhemaraRatanaram.org or WatKhmers.org

សម្បុប្ផិតក្កា តិដ្ឋន្តិ          បជ្ជលន្តេវ កឹសុកា ។
សេតបណ្ណិ សត្តបណ្ណា          កទលិយោ កុសុម្ភរា
ធនុតក្ការិបុប្ផេហិ          សីលចារណានិ ច ។
អច្ចិកា សិម្ពលីរុក្ខា          សល្លកិយោ ច បុប្ផិតា
សេតគេរូតករិកា          មំសិកោជ្ឈកុលាវរា ។
ទហរា រុក្ខា រុឡ្ហា ច          អកុដិលា ចេត្ត បុប្ផិតា
អស្សមំ ឧភតោ បន្តិ          អគ្យាគារំ សមន្តតោតិ ។

ព្រាហ្មណ ហៃព្រាហ្មណ៍អើយ រីឈើផងទាំងឡាយ សឹងដ៏ដុះរៀងរាយនៅសងខាងស្រះមុចលិន្ទនោះសោត សឹងដ៏មានដើមក្ទម្ពប្រទុំនីទៅនូវច្រនៀង ដុះរាលរៀងដោយអណ្តាប់ មានទាំងព្រីងព្រូស ជន្លួស ស្វាត ស្វាយ ដ៏មានផ្កាវីកស្គុះស្គាយត្រសាយលាស់ខ្ចី មានទាំងអង្គាដី ស្រឡី ផ្ចឹក រាំង ក្រសាំង ក្រូចថ្លុង ក្រូចឆ្មារ ដ៏មានពណ៌នោះល្អ ៗ នៅសងខាងស្រះមុចលិន្ទនោះហោង ។

ហៃព្រាហ្មណ៍អើយ មួយសោត រីជីរ-ស ជីរខ្មៅ ឈូក ត្រាញ់ នាកាលខ្យល់បក់មកផុំក្លិននីទៅនូវគន្ធពិដោរ ពួដ៏អាស្រមបទ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបាទស្រីវេស្សន្តរនោះហោង ។ នាសងខាងព្រះអាស្រមបទនោះ ដ៏ដុះដាសពាសពេញនីទៅនូវគណ្ឌីស គណ្ឌីខ្មៅ សឹងមានផ្ការីកស្គុះស្គាយពណ្ណរាយជាប្រក្រតី ។ ព្រាហ្មណ៍អើយ រីឈើផងទាំងឡាយដ៏មានសុក្រាំ ច្រឡាំនូវពពូលថ្ម ដកពរ ម្រុំ ភេកា ការកេស ចេកទេស កណិការ ចម្ប៉ា ចំប៉ី ច្បាទេស ។

ហៃព្រាហ្មណ៍អើយ រីឈើផងទាំងឡាយ ដ៏មានត្រយឹងកំភ្លឹង ក្តាំងងា ចារ ដ៏មានផ្ការីកដូចនឹងឆេះឡើង បិតនៅដោយសងខាងព្រះអាស្រមបទនោះហោង ។ ព្រាហ្មណ៍អើយ រីឈើផងទាំងឡាយ ដ៏មានសត្បារ-ស សត្បារខ្មៅ មានទាំងចេកមាសដុះដាសនៅដី មានទាំងអង្គាដី ស ក្រហម មានទាំងក្រិន្នា ពព្លា ផ្កាដកគាំ ដ៏រីកសន្ធៅឆ្អៅល្អ ដ៏មានទាំងគ្រញូង ទន្លា ខ្លង ត្បែង ពុំសែន សំរោងសំរង អំពៅព្រៃផង ទាំងក្រស្នាផងក៏មានច្រើន ។ រីឈើអស់នោះសោត ទោះបីទើបនឹងលំពង់ឡើយក្តី ទោះចាស់ក្តី សឹងតែស្លូតល្អ ដ៏មានចុងនោះត្រង់ល្អពុំមានវៀចឡើយ ។

អថេត្ថ ឧតកន្តស្មឹ ពហូ ជាតា ផណិជ្ជកា

Websites: WatKhemaraRatanaram.org or WatKhmers.org

មុត្តិយោ ការតិយោ   សេវាលំ សីសកំ ពហុ ។
ឧទ្ធាបវត្តំ ឧល្លុប្បិតំ   មក្ខិកា ហិង្គុជាលិកា
ជាសិមកញ្ញកោ ចេត្ថ   ពហូ នីចេ កលម្ពកា ។
ឯឡម្ពកេហិ សញ្ឆន្នា   រុក្ខា តិដ្ឋន្តិ ព្រាហ្មណ
សត្តាហំ ធារិយមានានំ   គន្ធោ តេសំ ន ឆិជ្ជតិ ។
ឧភតោ សរញ្ច មុចលិន្ទំ   បុប្ផា តិដ្ឋន្តិ ភាគសោ
ឥន្ទីវរេហិ សញ្ឆន្នំ   វនន្តមុបសោភតិ
អឌ្ឍមាសំ ធារិយមានានំ   គន្ធោ តេសំ ន ឆិជ្ជតិ ។
នីលបុប្ផិសេតវារី   បុប្ផិតា គិរិកណ្ណិកា
កលេរុក្ខេហិ សញ្ឆន្នំ   វនន្តំ តុលសីហិ ច ។
សម្មោទិតេវ គន្ធេន   បុប្ផសាខាហិ តំ វនំ
ភមរា បុប្ផគន្ធេន   សមន្តាមភិនាទិតា ។
តីណិ កក្ការុជាតានិ   តស្មឹ សរសិ ព្រាហ្មណ
កុម្ភមត្តានិ ចេកានិ   មុរមត្តានិ តា ឧភោ ។

ព្រាហ្មណ៍អើយ វីស្រះនោះសោត ដ៏មានកំពីងពួយវារ វ័ណ្ឌព័ទ្ធលើស្មៅ ឮដ៏ទឹករាក់ជ្រៅ វីផ្ទេរស្រះសោតមានទាំងសណ្តែក បាយ ប្រពាយទេសផងច្រើន ។ ព្រាហ្មណ៍អើយ វីមុចលិន្ទស្រះនោះ មានកំពង់នោះរាប ច្រាំងនោះទាបស្រណុក បើខ្យល់បក់ទៅមក ដ៏ មានរលកខ្វាយខ្វរឡើង វីមេឃុំក៏ហើរមកប្រព្យាយត្រើបយកកេសរភ្ញី ផង ។ មួយសោត ព្រាហ្មណ៍អើយ វីស្លាស្នាប់ ស្លាធំ ម្លូភ្នំផងច្រើន សឹងដ៏មានទាំងសសិតទេស សសៀតទៃ មានឮដ៏ឋាននោះ ។

ព្រាហ្មណ៍អើយ វីឈើអែមផង សឹងដ៏មានផ្លែផ្កានៅឮដ៏ មុចលិន្ទស្រះនោះ ទោះអ្នកឯណាទៅដល់យល់ហើយ ក៏បេះប្រឡេះ មកទ្រង់លុះអស់ ៧ ថ្ងៃក្តី ក៏ក្លិនពិដោរអប់ត្រឡប់នោះ មិនចេះហៅ ស្បើយល្ហើយឡើយ ។ ព្រាហ្មណ៍អើយ វីអញ្ចូនស អញ្ចូនខ្មៅ អញ្ចូន លឿង ដ៏មានផ្ការីករុងរឿងនីទៅនូវម្លិះរួត ម្លិះលា យុថ្កា ពុកឆ្មា ម្រះព្រៅ លីងល័ខ ស្លឹកគ្រៃផងច្រើន ។ ម្នាលព្រាហ្មណ៍អើយ វីព្រៃ នោះសប្បាយគាប់ចិត្តពេក វីកន្លង់ផងហើរទៅមក ត្បឹបជញ្ជក់យក កេសរភ្ញីនោះ ឮសូរសព្ទពីរោះដូចអ្នកប្រគំ គង ភេរី តូរ្យតន្ត្រីនៅនាសួគ៌

Websites: WatKhemaraRatanaram.org or WatKhmers.org

នាយហោង ។

ព្រាហ្មណ៍អើយ រីមុចលិន្ទស្រះនោះសោត ដ៏មានកំណើតត្រឡាចផងមាន ៣ ជំពូក គឺត្រឡាចមួយមានផ្លែធំប៉ុនស្គរជ្វា ឯត្រឡាចពីរ (ជំពូក) នោះសោត សឹងមានផ្លែប៉ុនសម្ភោរ សឹងដុះរៀបរៀងនាសងខាងឆ្នេរស្រះនោះឯង ។

អចេត្ថ សាសថោ ពហុកោ   ជាតិយោ ហរិតា យុតោ
អសី តាលាវ តិដ្ឋន្តិ   ឆេជ្ជា ឥន្ទិវរា ពហូ ។
អច្ឆោជា សុរិយវល្លី ច   កាឡិយា មធុគន្ធិយា
អសោកា មុទយន្តី ច   វល្លិកោ ខុទ្ទបុប្ផិយោ ។
កោរណ្ឌកា អនោជា ច   បុប្ផិតា ជាតមល្លិកា
រុក្ខមារុយ្ហ តិដ្ឋន្តិ   ផុល្លា កឹសុកវល្លិយោ ។
កាដេរុហា បរាសេន្តិ   យោធិកា មធុគន្ធិយា
និលិយា សុមនា ភណ្ឌី   សោភតិ បទុមុត្តរោ ។
ចាដលិសមុទ្ទកប្បាសី   កណិការា ច បុប្ផិតា

Websites: WatKhemaraRatanaram.org or WatKhmers.org

ហេមជាលាវ ជិស្សន្តិ រុចិរា អគ្គិសិខូបមា ។
យានិ តានិ ច បុប្ផានិ ថលជានូទកានិ ច
សព្វានិ តត្ថ ទិស្សន្តិ ឯវំ រម្មោ មហោទធីតិ ។

ព្រាហ្មណ៍អើយ នៅជិតស្រះនោះ មានទាំងស្ពៃ ជីរលើង ល័ខ រំដេង ខ្ទាយ ខ្ទឹទឹក ខ្ទឹភ្លើង ខ្ទឹមស ខ្ទឹមក្រហម មើមប្លុងផង ច្រើន មានទាំងដើមត្រៀក កម្រៀក ត្រសេក ផ្ទឹក ត្រយឹង តាត្រៅ មានទាំង ឈើអែមឱទ្យោក ទៀនព្រៃ ស្រឡី ស្រឡៅ ផ្តៅឆ្វាំង ទាំងចង្កូមស្វា ខ្នាផង មានទាំងផ្កាទេស ឈើកេស ប្រមោយដំរី ស្បែង ទ្រមែង ស្មៃ ស្មាច់ ជម្ពូព្រឹក្ស អធិកន្ទរព្រៃ រៃពោក កន្ទ្រោក កកោះ រលួស រលាយ ពោធិបាយ ត្រសាយសាខា មានទាំងត្រុំព្រៃ ចិត្តបុស្ស បោះ ស្វា ប្រោះជា ឈូកត្រាញ់ ភង្គី អាគ្នេយ៍ឃ្វាល សហស្សគុណ ទន់ដី ច្រនៀង រវៀង ដកពរ ពពូលថ្ម រំដេញ ប្រផេញ ត្រៀលសឹងមានគ្រប់ ពណ៌ ។ ហៃព្រាហ្មណ៍អើយ រីកំណើតផ្កាផងទាំងឡាយ នាលើគោក ក្តី ក្នុងទឹកក្តី រីអស់ផ្កាផងនោះសឹងដ៏យល់ប្រាកដពេក។ ឯទឹកមុចលិន្ទ ស្រះនោះសោត សឹងដ៏ពិដោរថ្លាត្រជាក់ កំពង់រាប ច្រាំងនោះទាប

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រណុកសប្បាយដោយនូវប្រការដូច្នេះហោង ។

អជស្សា ចោក្ខរណិយា    ពហុកា វារិគោចរា
រោហិតា នលបេសិង្គូ    កុម្ភិលា មករា សុសូ ។
មធុ ច មធុលដ្ឋិ ច    តាលីយា ច បិយង្គុកា
កុន្ទជា ភទ្ទមុដ្ឋា ច    សត្តបុប្ផា ច សោលុចា ។
សុរភិមរុតតកា    ពហុកា តុង្គវណ្ដិយោ
បទ្មកា ឆារជា កោដ្ឋា    ឈាមកា ច ហរេណុកា ។
ហលិទ្ទកា គន្ធសេលា    ហរិវេរា ច គុគ្គុលា
វិភេទកា ចោរកោដ្ឋា    កប្បុរា ច កលិង្គុកាតិ ។

ហៃព្រាហ្មណ៍អើយ  វីក្នុងទឹកស្រះបោក្ខរណីនោះសោត  ដ៏មានត្រីឆ្តោក ត្រីឆ្ពិន ត្រីច្រកែង ត្រីអណ្ដែង ត្រីប្រាទីពោ ឆ្តោ រាហូ នូវក្រពើ ឆ្លាម មករ ផ្សោតផង វីអស់ត្រីតូចធំផង សឹងហែបហែលទៅមកឰដ៏កំឡុងស្រះនោះហោង ។ ព្រាហ្មណ៍អើយ វីឆ្នេរស្រះបោក្ខរណីនោះសោត  ដ៏មានឃ្មុំធំ  ឃ្មុំផ្លិត ទំដោយឈើប្រយង្គុ ខ្លែងគង់ ក្រវាញ ក្រវាន់ ក្លាំពូ សំបូណ៌ល្វែង សូរភី កំញ៉ាន មានទាំងវល្លិ៍បណ្តូលពេជ

Websites: WatKhemaraRatanaram.org or WatKhmers.org

រំលេចទាំងទេពទារូ មានទាំងដើមកោដ្ឋ កន្ទួត លោត ហរតាន គ្រើល ក្រុង រង់ ព្រហូត ពពូល ពពាលខែ ដីប្លី ដ៏មានទាំង កបូរ ចន្ទន៍ស ចន្ទន៍ក្រហម ។ ព្រាហ្មណ៍អើយ បើអ្នកឯណាមួយធ្វើសីលសូត្រមន្ត ភាវនានៅនាព្រៃនោះ ក៏ស្រណុកសុខសប្បាយពេកហោង ។

អថេត្ថ សីហា ព្យគ្ឃា ច　　　បុរិសាលូ ច ហត្ថិយោ
ឯណេយ្យា បសទា ចេវ　　　រោហិតា សរភា មិគា ។
កោដ្ឋសុណា សុណោបិ ច　　　តុលិយា នឡសន្និភា
ចាមរី ចលនី លង្ឃី　　　ឈាបិតា មក្កដា បិចុ
កក្កដា កតមាយា ច　　　ឥក្កា គោណសិរា ពហូ
ខគ្គា វរាហា នកុលា　　　កាឡកោត្ថ ពហុតសោ ។
មហិសា សោណា សិគាលា　　　ចប្បកា ច សមន្តតោ
អាកុច្ឆា បចលាកា ច　　　ចិត្រកា ចាបិ ទីបិយោ
បេលកា ច វិឃាសាទា　　　សីហា គោកនិសាតកា
អដ្ឋចាទា ច មោរា ច　　　ភស្សរា ច កុក្កុដ្ឋកា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ចង្កោរា កុក្កុដា នាគា អញ្ញមញ្ញំ បកោជិនោ
ពកា ពលាកា នជ្ជុហា ទិន្ទិភា កោញ្ចវាទិកា ។
ព្យគ្ឃិនសា លោហបិដ្ឋា ចប្បកា ជីវជីវកា
កបិញ្ជរា តិត្តិរាយោ កុលាវា បដិកុត្ថកា ។
មណ្ឌាលកា ចេលកេឡុ ភណ្ឌុតិត្តិរនាមកា
ចេលាវកា បិង្គុលាយោ គោដកា អង្គហេតុកា ។
ករវិកា ច សក្កា ច ឧហុង្ការា ច កុក្កុហា
នានាទិជគណាកិណ្ណំ នានាសរនិកូជិតន្តិ ។

ព្រាហ្មណ៍អើយ វីសត្វព្រៃផងទាំងឡាយ គឺរាជសីហ៍ ដំរីសិង្ហ រមាស ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ មានទ្រាយ ទន្សោង ឈ្លូស រមាំងប្រើស គោព្រៃ ខ្ទីង ចចក ស្វាន ស្វា មាន ទាំងកំប្រុក ឆ្មាបា ចាមរី ល្មីកុញ្ជរ ស្វាខោ ស្វាឪ ស្វាស្រូវ ស្វាអង្គត់ ស្វាព្រាម ជ្រូកព្រៃ មានទាំងសំពោច ទោច ឪឡ ត្រកួត ទន្សង បង្កួយផង សឹងបិតនៅខាងអាស្រមបទព្រះបាទស្រីវេស្សន្តរនោះហោង ។ បក្ខិនោ មួយសោត វីពួកបក្សាបក្សីផងទាំងឡាយ ដ៏មានសត្វឥន្ទ្រី ត្មាត ខ្លែងស្រាក ខ្លែងខ្មោច

ទីទុយ ក្ងោក ក្ងាន ប៉ោលតោក តាវៅ ស្ទិតថៅ មានទាំងហង្ស អាឧដ្ឋ មាន់ទោ មាន់ទឹក ប្រវឹក មាន់ព្រៃ ចចាត ច្រឡៃ សេកផង មានទាំងកុក គ្រោង កុកសាប់ កុកស ក្ង ក្រៀល ចង្រៀលខ្យង ក្រួច កង្កួច កង្កែង ព្រះឥន្ទស្ទាំង ភ្វាំង ត្រដេវរ៉ិច តាដក់ ត្លុម រនាល ត្រយង ខ្លែង ស្រាក ក្រសារ ទុង ទោម ទទា ចេកទុំ គ្រលេងគ្រលោង ចាបព្រៃ គ្រលែងវែកផង ។

អថេត្ថ សកុណា សន្តិ    នីលកា មញ្ជុភាណិកា
មោទន្តិ សហ ភរិយាហិ    អញ្ញមញ្ញំ បកូជិនោ ។
អថេត្ថ សកុណា សន្តិ    ទិជា មញ្ជុស្សរាសិតា
សេតក្ខិកូដា ភទ្រក្ខា    អណ្ឌជា ចិត្របេក្ខុណា ។
អថេត្ថ សកុណា សន្តិ    ទិជា មញ្ជុស្សរាសិតា
សិខណ្ឌី នីលគីវាហិ    អញ្ញមញ្ញំ បកូជិនោ ។
កុក្កុដ្ឋកា កុឡីរកា    កោដ្ឋា ពោក្ខរសាតកា
កាលេយ្យា ពលីយក្ខា    កទម្ពា សុវសាលិកា ។
ហលិទ្ទា លោហិតា សេតា    អថេត្ថ នឡកា ពហូ

Websites: WatKhemaraRatanaram.org or WatKhmers.org

វារណា ភិង្ការជា ច　　កទម្ពា សុវកោកិលា ។
ឧក្កុសា កុរុរា ហំសា　　អាដា បរិវទេន្តិកា
ចាកហំសា អតិពលា　　នជ្ជុហា ជីវជីវកា ។
ចាបេវតា រវិហំសា　　ចាកវាកា នទីចរា
វារុណាភិរុទា រម្មា　　ឧភោ កាលុបកូជិនោ ។
អថេត្ថ សកុណា សន្តិ　　នានាវណ្ណា ពហូ ទិជា
មោទន្តិ សហ ភរិយាហិ　　អញ្ញមញ្ញំ បកូជិនោ ។
អថេត្ថ សកុណា សន្តិ　　នានាវណ្ណា ពហូ ទិជា
សព្វេ មញ្ជូ និក្កូជន្តិ　　មុចលិន្ទមុភតោ សរំ ។
អថេត្ថ សកុណា សន្តិ　　ករវីកា នាម តេ ទិជា
មោទន្តិ សហ ភរិយាហិ　　អញ្ញមញ្ញំ បកូជិនោ ។
អថេត្ថ សកុណា សន្តិ　　ករវីកា នាម តេ ទិជា
សព្វេ មញ្ជូ និកូជន្តិ　　មុចលិន្ទមុភតោ សរំ ។
ឯណេយ្យបសទាកិណ្ណំ　　នាគសំសេវិតំ វនំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឆានាលតាហិ សញ្ឆន្នំ កាឧលិមិកសេវិតំ ។
អថេត្ថ សាមា ពហុកា ធិវាហេ វរកោ ពហុ
សាលិ អកដ្ឋបាកោ ច ឧច្ឆុ តត្ថ អឧប្បកោ ។
អយំ ឯកបធី ឯតិ ឧជុំ កច្ឆតិ អស្សមំ
ខុទ្ទំ បិបាសំ អរតឹ តត្ថ បត្តោ ន វិន្ទតិ ។
យត្ថ វេស្សន្តរោ រាជា សហ បុត្តេហិ សម្មតិ
ធារេន្តោ ព្រាហ្មណវណ្ណំ អាសទញ្ច មសញ្ចជំ
ជម្មាសី ធមា សេតិ ជាតវេទំ ធមស្សតីតិ ។

ព្រាហ្មណ៍អើយ រីអស់សត្វបក្សីផងទាំងឡាយ មាននៅនាព្រៃនោះគឺ សារិកាកែវយំដ៏មានសម្លេងនោះពីរោះស្មោះ បីដូចជាលោកអ្នកប្រាជ្ញ រាជបណ្ឌិតទេសនាធម៌ដ៏ប្រសើរ មុខគួរឲ្យត្រេកអរស្តាប់នូវសព្ទនោះពីរោះពេកហោង ។ រីអស់សត្វបក្សីទាំងនោះសោតដ៏មានកំណើតនោះពីរដង គឺពងហើយញាស់ចេញមកជាកូន សឹងមានរបៀបស្លាបនូវកន្ទុយនោះល្អឥតត្លងឡើយ ហើយស្រែកនូវសព្ទសម្រែកបន្លឺទៅវិញទៅមក នៅនាព្រៃនោះឯង ។ ព្រាហ្មណ៍អើយ រី

Websites: WatKhemaraRatanaram.org or WatKhmers.org

សត្វទាំងឡាយ គឺប្រមង់ រអាត ខ្លែងស្រាក ក្អែកទឹក ប្ររឹក លលកមៀម មានទាំងសេកឃា សេកសោមបណ្ឌិត សេកស មានរំពៃកណ្ដឹងប្រមា ទោច ខ្លែងខ្មោច ឪឡ ភូរាំង ឥន្ទ្រី ចាមរី មានទាំងហង្សខៀវ ហង្សលឿង ហង្សស មានទាំងឧកអក សម្បុក ទំពាំង ស្វាំងតាវៅ ព្រហីត ស្វិតថៅ ព្រាបផង មានទាំង ចាកក្រពាក ទាំងស្មោញទាំងខ្សឹង គឺខ្សឹងហៀន ខ្សឹងដែកចារ លៀស គ្រំ គ្រែង ខ្សឹងមុខផង ។ ព្រាហ្មណ៍អើយ កាលណាបើថ្ងៃរសៀលទន់ទៀបទៅហើយក្ដី អស់រំពៃកណ្ដឹងវាយំឮពីរោះមុខគួរឲ្យស្រណោះពេក ។ ព្រាហ្មណ៍អើយ វីសត្វទាំងឡាយនេះ សឹងកាច់សម្បុកទុកពង នៅសងខាងស្រះមុចលិន្ទនោះ ។ វីសត្វនាមហៅករវិកនោះសោត សឹងយំឮសព្ទឆ្លើយឆ្លងគ្នាទៅមក សឹងតែមុខគួរឲ្យស្រណោះពេក ។ ព្រាហ្មណ៍អើយ នៅខាងអាស្រមបទ លំនៅព្រះបាទស្រីវេស្សន្តរនោះ ដ៏ពេញនីទៅនូវពពួកម្រឹគផងផ្សេងៗ គឺសំពោច នូវស្វា វាលេងបន្លែងប្រចាប់ចំបាប់គ្នាដោយភាសាវា ។ ព្រាហ្មណ៍អើយ វីសងខាងស្រះនោះដ៏មានផ្ដៀកផ្ដៅស្មៅជើងក្រាស់លាស់ខ្ចី ស្រូវភោជន៍សាលី សឹងដុះឯង ទុំជ្រុះឯង ឥត

Websites: WatKhemaraRatanaram.org or WatKhmers.org

អ្នកណាមួយទៅបង្កើតឡើយ រីអំពៅផងនោះសោត ដ៏មានពណ៌នោះផ្សេងៗ គឺអំពៅថ្នាំងវែង អំពៅតម្លាន់ ។ ព្រាហ្មណ៍អើយ បើអ្នកឯណាមួយដើរទៅដល់យល់ហើយ ដ៏បរិភោគឥតស្រេកឃ្លាន ដ៏មានចិត្តនោះក្សេមក្សាន្ត ពុំចង់ដើរចេញឡើយ ។ ហៃព្រាហ្មណ៍អើយ រីផ្លូវនឹងដើរទៅកាន់អាស្រមបទ ព្រះបាទស្រីវេស្សន្តរនោះ ចង្អៀតចុះដើរតែជើងអ្នកមួយដើរទៅក្តី ដើរមកក្តី ។ ព្រាហ្មណ៍អើយ រីព្រះបាទស្រីវេស្សន្តរបវរបរមពោធិសត្វ ស្តេចចេញមកសាងព្រះផ្នួសបួសមួយអន្លើនឹងព្រះរាជបុត្រព្រះរាជទេពី ដ៏មានព្រះហស្តនោះកាន់ទំពក់ថ្ពក់ផ្លែឈើផង ចងព្រះកេសាជដាមណ្ឌល ហើយទ្រង់នូវស្បែកខ្លាទាំងក្រចកក្រវាត់ស្បូវភ្លាំង សំពះព្រះភ្លើងតាងចីវរព្រះបច្ចេកពោធិហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថាដូច្នេះ ៖

ឥទំ សុត្វា ព្រហ្មពន្ធុ ឥសី កាត្វា បទក្ខិណំ
ឧទគ្គចិត្តោ បក្កាមិ យត្ថ វេស្សន្តរោ អហុ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ហៃភិក្ខុអើយ វីជូជកព្រាហ្មណ៍ ជាសន្តានស្មូមនោះ លុះបានស្តាប់ពាក្យអច្ចុតមហាឫសីហើយ ក៏មានចិត្តនោះត្រេកអរ សាទរធ្វើប្រទក្សិណ ៣ ជុំ ហើយក៏លាចេញទៅ ។ វីព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ស្តេចគង់សាងព្រតត្រង់ឋានឯណាមិញ ក៏ជូជកព្រាហ្មណ៍នោះ ឆ្ពោះមុខទៅត្រង់ឋាននោះហោង ។

ឥតិ ឥមស្មឹំ មហាវេគណ្ណោ អសីតិគាថាបដិមណ្ឌិតា មហាវេវណ្ណនា និដ្ឋិតា ហៃសាធុសប្បុរសផងទាំងឡាយអើយ អាត្មាភាពសំដែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក កណ្ឌមហាពន ដ៏ប្រដាប់ប្រដានូវគាថាទាំងឡាយ ៨០ គាថានេះមិញ ជាគ្រឿងប្រដាប់សទ្ធាជ្រះថ្លានៃពួកឧបាសកឧបាសិកា ឯវំ ក៏ចប់ដោយសមគួរនៅវេលានេះឯងហោង ៕៚

(ចប់កណ្ឌមហាពន ទី ៧ តែប៉ុណ្ណោះ)

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយខំព្យូទ័រសាឡើងវិញ
ដោយ
**លោកគ្រូអាចារ្យ ឈឹម សំបូរ**
និង
ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ
ដោយ
លោកគ្រូ **ធម្មនាថ ផនប្រសិទ្ធិ៍**
ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ
សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង

Websites: WatKhemaraRatanaram.org or WatKhmers.org

ញ៉ុក ‧ ថែម

# មហាវេស្សន្តរជាតក



កណ្ឌទី ៧

ផ្សាយលើកទី "[illegible]"
រក្សាសិទ្ធិគ្រប់យ៉ាង
ព.ស ២៥៤៦ គ.ស ២០០២